Independent office of evaluation

IFAD

Investing in rural people

# Country Strategy and Programme Evaluation

## Kingdom of Cambodia

Summary (Khmer)



## ព្រះរាជាណាចក្រកម្ពុជា
## យុទ្ធសាស្ត្រជាតិ និងការវាយតម្លៃកម្មវិធី
## សេចក្តីសង្ខេប (និដ្ឋភាពទូទៅ)

### ក. សាវតា

១. នៅឆ្នាំ២០១៧ ការិយាល័យវាយតម្លៃឯករាជ្យរបស់ IFAD បានធ្វើការវាយតម្លៃលើយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស (CSPE) ជាលើកទី១ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ ការវាយតម្លៃលើយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសនេះ បានពិនិត្យឡើងវិញនូវការវិវត្តន៍នៃយុទ្ធសាស្ត្រ លទ្ធផល និង ការអនុវត្តភាពជាដៃគូ រវាង IFAD និង រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីមូលនិធិនេះ បានចាប់ផ្តើមប្រតិបត្តិការ នៅឆ្នាំ១៩៩៧ ប៉ុន្តែ ផ្តោតលើរយៈពេលមួយទសវត្សចុងក្រោយ ជាពិសេស ជាមួយនឹងផលប័ត្រនៃការវិនិយោគ។ ការវាយតម្លៃលើយុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេសនេះ គ្របដណ្តប់ផលប័ត្រនៃការវិនិយោគ (គម្រោងចំនួន៧ ដែលត្រូវបានអនុម័តនៅចន្លោះឆ្នាំ២០០០ និង ២០១៦) រួមទាំងសកម្មភាពបន្ថែម (មិនមែនកម្ចី) (ការគ្រប់គ្រងចំណេះដឹង ការកសាងភាពជាដៃគូ និង ការពិគ្រោះយោបល់ផ្នែកគោលនយោបាយ រួមទាំងជំនួយឥតសំណង) ក៏ដូចជាយុទ្ធសាស្ត្រ និងការគ្រប់គ្រងកម្មវិធីនានារបស់ប្រទេស។

២. **គោលបំណង:** ការវាយតម្លៃលើយុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស មានគោលបំណងសំខាន់ពីរ គឺ: (១) ដើម្បីវាយតំលៃលទ្ធផល និងការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីនានាដែលប្រើប្រាស់ហិរញ្ញប្បទានរបស់ IFAD និង (២) បង្កើតឲ្យមានរបកគំហើញ និងអនុសាសន៍នានាសម្រាប់ភាពជាដៃគូនាពេលអនាគត រវាង IFAD និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកំពស់ប្រសិទ្ធផលនៃការអភិវឌ្ឍន៍ និងការលុបបំបាត់ភាពក្រីក្រនៅជនបទ។

៣. **ដំណើរការនៃ**ការវាយតម្លៃលើយុទ្ធសាស្ត្រនិង**កម្មវិធីប្រចាំប្រទេស:** ការវាយតម្លៃលើយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស ត្រូវបានរៀបចំឡើង ជាច្រើនដំណាក់កាល។ ដំណាក់កាលទី ១ គឺជាបេសកកម្មត្រៀមរៀបចំនៅប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី២៣ ខែមករា ដល់ថ្ងៃទី៣ ខែ កុម្ភៈ ឆ្នាំ២០១៧ ការពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ និង ការរៀបចំឯកសារអភិក្រមយុទ្ធសាស្ត្រ និងការវាយតម្លៃកម្មវិធីប្រចាំប្រទេស។ ក្រៅពីបេសកកម្មរៀបចំ មានបេសកកម្មសំខាន់មួយទៀត បានធ្វើឡើង នៅខែឧសភា ឆ្នាំ២០១៧ គឺ ការវាយតម្លៃលើការអនុវត្តគម្រោងស្តីពីការកែលម្អជីវភាពរស់នៅតាមជនបទ នៅខេត្តក្រចេះ ព្រះវិហារ និង រតនគិរី ត្រូវបានធ្វើនៅខែមិនា ឆ្នាំ២០១៧ ដើម្បីដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រ និង ការវាយតម្លៃកម្មវិធីប្រចាំប្រទេស។ បេសកកម្មដ៏សំខាន់នៃការវាយតម្លៃលើយុទ្ធសាស្ត្រ និង កម្មវិធីប្រចាំប្រទេស ត្រូវបានធ្វើនៅទីវាលពីថ្ងៃទី១ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ហើយមានរៀបចំកិច្ចប្រជុំនានា នៅរាជធានីភ្នំពេញ ក៏ដូចជាការធ្វើទស្សនកិច្ចនៅទីវាល តាមខេត្ត ចំនួន១០ ដោយក្រុមការងារចំនួន២។

៤. **បរិបទនៃការវិវត្តរបស់ប្រទេស:** IFAD បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនក្នុងប្រទេសកម្ពុជា នៅឆ្នាំ១៩៩៦ នៅពេលដែលមានការស្ថាបនា និងការស្តារឡើងវិញក្រោយពីសង្គ្រាម និងការបំផ្លិចបំផ្លាញ ជិតពីរទសវត្សរ៍។ ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជា និង បរិបទជនបទបានផ្លាស់ប្តូរយ៉ាងខ្លាំង។ ព្រះរាជា

ណាចក្រកម្ពុជា មានកំណើនសេដ្ឋកិច្ចខ្ពស់។ កម្រិតនៃភាពក្រីក្រ បានថយចុះពីប្រមាណ ៥០% ក្នុងឆ្នាំ ២០០៧ មកត្រឹម ១៣,៥% ក្នុងឆ្នាំ២០១៤។ ប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទបានកើនឡើង ដោយមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ក្នុងសមាសភាពនៃប្រភពចំណូលៈ គ្រួសារក្រីក្រនៅជនបទជាច្រើន បានចូលរួមកាន់តែច្រើនឡើងក្នុងការងារដែលមានប្រាក់ខែក្នុងវិស័យសំណង់ និង ឧស្សាហកម្មកាត់ដេរក្នុងស្រុក ឬតាមរយៈការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដែលបង្កឲ្យមានកង្វះកម្លាំងពលកម្មនៅតំបន់ជនបទ។ កំណើនកសិកម្មជាបន្តបន្ទាប់ ក៏បានរួមចំណែកផងដែរដល់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ថ្វីបើកម្រិតនៃកំណើននេះ បង្ហាញនិន្នាការធ្លាក់ចុះក្នុងរយៈពេលពីរឬបីឆ្នាំកន្លងមកនេះក៏ដោយ។ ភូមិជាច្រើនមានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មហិរញ្ញវត្ថុប្រសើរជាងមុនគួរឲ្យកត់សំគាល់។

**៥. IFAD នៅកម្ពុជាៈ** ព្រះរាជាណាចក្រកម្ពុជា បានក្លាយជាសមាជិកមួយរបស់ IFAD នៅឆ្នាំ១៩៩២ ភ្លាមៗ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាព ក្នុងឆ្នាំ១៩៩១។ បន្ទាប់មក IFAD បានអនុម័តប្រាក់កម្ចីលើកដំបូងក្នុងឆ្នាំ១៩៩៦ ដើម្បីផ្តល់សហហិរញ្ញប្បទានគម្រោងជាមួយធនាគារពិភពលោក ហើយរហូតមកដល់ពេលបច្ចុប្បន្ន IFAD បានគាំទ្រគម្រោងវិនិយោគចំនួន៩ សម្រាប់ទឹកប្រាក់គម្រោងសរុបមានតម្លៃ ៣៥៣,៩ លានដុល្លារអាមេរិក ជាមួយនឹងការចូលរួមចំណែកហិរញ្ញប្បទានចំនួន ១៧៩,៥ លានដុល្លារអាមេរិក រួមទាំងជំនួយឥតសំណងចំនួន ៥០ លានដុល្លារអាមេរិក[1] ។ ចំនួនអ្នកទទួលផលសរុបដែលបានប៉ាន់ប្រមាណនៅដំណាក់កាលតាក់តែងគម្រោងទាំង ៩ នេះ គឺប្រហែល ៥,៦៩ លាននាក់ (១,២៨ លាន គ្រួសារ)។

**៦.** IFAD មានយុទ្ធសាស្ត្រប្រចាំប្រទេសចំនួនបី (កម្មវិធី/ឯកសារឱកាសយុទ្ធសាស្ត្រប្រចាំប្រទេស COSOPs) ដែលបានរៀបចំនៅឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និងឆ្នាំ២០១៣។ ការផ្តោតការយកចិត្តទុកដាក់ និងវិធីសាស្ត្រនៃកម្មវិធីប្រចាំប្រទេស បានវិវដ្ត និង សម្របខ្លួនទៅនឹងតម្រូវការដែលកំពុងកើតឡើង និងបទពិសោធន៍របស់ IFAD នៅក្នុងប្រទេស។ ឯកសារកាលានុវត្តភាពយុទ្ធសាស្ត្រប្រចាំប្រទេសឆ្នាំ១៩៩៨ និង២០០៨ ផ្តោតលើវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ តាមរយៈ វិធីសាស្ត្រវិមជ្ឈការ ដែលរួមចំណែកដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការ (D&D)" ។ ឯកសារកាលានុវត្តភាពយុទ្ធសាស្ត្រប្រចាំប្រទេស ឆ្នាំ២០១៣ បង្ហាញពីការផ្លាស់ប្តូរពីវិធីសាស្ត្រនៃជីវភាពរស់នៅ ទៅរកការតម្រង់ទិសទីផ្សារ ពីការលើកកម្ពស់សេវាវិមជ្ឈការសាធារណៈ ទៅជាគោលគំនិតទូលំទូលាយនៃការផ្តល់សេវានៅតាមជនបទដែលគាំទ្រអ្នកក្រីក្រដែលមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និង ការផ្តោតយកចិត្តទុកដាក់ជាក់លាក់បន្ថែមទៀត លើភាពធន់របស់គ្រួសារជនបទក្រីក្រ។

## ខ. ការអនុវត្តផលប័ត្រវិនិយោគ

**៧. ភាពពាក់ព័ន្ធៈ** ការតម្រង់ទិសគម្រោងទាំងមូល ត្រូវបានអនុលោមទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង IFAD ជាពិសេស ទាក់ទងនឹងការគាំទ្រដល់វិស័យកសិកម្មដោយផ្តោតលើការកែលម្អផលិតភាព និងការធ្វើប្រពលវប្បកម្ម ព្រមទាំងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ ជាពិសេស ការគាំទ្រដល់វិមជ្ឈការ គឺជាធាតុផ្សំដែលអាចមើលឃើញភាគច្រើនបំផុតនៅក្នុង

[1] ហិរញ្ញប្បទានឥតសំណងក្រោមក្របខ័ណ្ឌនិរន្តរភាពបំណុល និង ការបន្សាំសម្រាប់កម្មវិធីកសិកម្មខ្នាតតូច។

ផលប័ត្រដំបូងៗ និង មានការពាក់ព័ន្ធខ្លាំងទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

៨. **ក្នុងពេលជាមួយ**គ្នានេះ ការរៀបចំផលប័ត្រ មានភាពយឺតយ៉ាវក្នុងការទទួលស្គាល់ការផ្លាស់ប្តូរសំខាន់ៗ នៅក្នុងបរិបទជនបទ ដូចជា: (១) ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រភពចំណូលមិនមែនកសិកម្ម និងការធ្វើចំណាកស្រុកដែលបង្កើតឱ្យមានការខ្វះខាតកម្លាំងពលកម្មនៅតាមភូមិ និង ធ្វើឱ្យមានការពាក់ព័ន្ធកាន់តែច្រើនដល់ការយកចិត្តទុកដាក់ទៅលើផលចំណេញពីពលកម្មជាជាងលើទិន្នផលដំណាំ និង (២) ដំណើរការយ៉ាងឆាប់រហ័សនៃការផ្តល់សេវាហិរញ្ញវត្ថុដែលបានផ្តល់ឱ្យកាន់តែច្រើនឡើង ដែលបច្ចុប្បនេះ ភូមិភាគច្រើនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ការផ្លាស់ប្តូរចុងក្រោយនេះ មានន័យថាការគាំទ្រសម្រាប់មូលនិធិបង្វិលតាមក្រុម (GRFs) ដែលត្រូវបានគេអនុវត្តសារចុះសារឡើងនៅក្នុងគម្រោងជាច្រើនកន្លងមក បានក្លាយជាកម្មវិធីមានការពាក់ព័ន្ធតិចតួច/មិនសូវសំខាន់ចាំបាច់ នៅពេលនេះ។ ការយកចិត្តទុកដាក់ក្នុងការទទួលបានទីផ្សារដែលត្រូវបានគេមើលឃើញនៅក្នុងគោលនយោបាយ និង យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ថាមានភាពទន់ខ្សោយនៅក្នុងគម្រោងមុនៗ។

៩. លើកលែងតែគម្រោងថ្មីបំផុតចំនួនពីរ គម្រោងទាំងឡាយនេះ បានអនុវត្តវិធីសាស្ត្រតូចចង្អៀត និងលម្អិតសម្រាប់ការផ្តោតលើការជួយជនក្រីក្រនៅតាមជនបទ ប៉ុន្តែ ការកំណត់អត្តសញ្ញាណអ្នកទទួលផលផ្សេងៗទៀត មិនតែងតែត្រូវបានផ្តល់នូវជំនួយគាំទ្រសមស្របនោះទេ។

១០. **ប្រសិទ្ធផល:** គម្រោងទាំងឡាយនេះ ជំរុញឲ្យមានការកែលម្អបច្ចេកទេសកសិកម្មសំខាន់ៗ តាមរយៈការបណ្តុះបណ្តាល និងការពង្រីកសេវាកម្មបន្ថែម ដែលជារឿយៗ អមទៅជាមួយដោយការគាំទ្ររបស់ GRF។ ការទទួលបានលទ្ធផលតិចជាងការរំពឹងទុកនៃបច្ចេកទេសដែលបានកែលម្អដោយកសិករ គឺ មួយផ្នែកបណ្តាលមកពីភាពទន់ខ្សោយនៃវិធីសាស្ត្របណ្តុះបណ្តាល និងសេវាផ្សព្វផ្សាយកសិកម្ម មួយផ្នែកទៀត គឺដោយសារការខ្វះលក្ខខណ្ឌអំណោយផល (ឧ. ខ្វះលទ្ធភាពទទួលបានទឹក ការខ្វះខាតកម្លាំងពលកម្ម)។ ការយកចិត្តទុកដាក់ ទៅលើលក្ខណៈផ្សព្វផ្សាយកសិកម្ម និងបណ្តុះបណ្តាលដែល "ផ្អែកតាមតម្រូវការ" គឺជាស្នូលនៃគម្រោងទាំងឡាយនេះ ប៉ុន្តែ ភាគច្រើន ការបណ្តុះបណ្តាល មានទំនោរពីលើចុះក្រោម និង ផ្អែកលើការផ្គត់ផ្គង់ (ឧ. វគ្គបណ្តុះបណ្តាលភាគច្រើន គឺ ផ្អែកលើកញ្ចប់ស្តង់ដារ)។ ទោះជាយ៉ាងណាក្តី មានភាពល្អប្រសើរឡើងច្រើន ក្នុងវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម និងការបណ្តុះបណ្តាលក្នុងគម្រោងថ្មីៗនេះ។

១១. កម្ចីរបស់ GRF ទំនងជាបានគាំទ្រដល់ការអនុវត្តបច្ចេកវិទ្យាកសិកម្មដែលបានកែលម្អ ក៏ប៉ុន្តែ ទំនាក់ទំនងនេះមិនខ្លាំងក្លាដោយសារតែមានការផ្លាស់ប្តូរបរិបទ។ ដោយមានប្រាក់ចំណូលកើនឡើង ការផ្ញើប្រាក់ពីបរទេស និងប្រភពប្រាក់កម្ចីផ្សេងៗទៀត កម្ចីរបស់ GRF បានក្លាយទៅជាប្រភពមួយក្នុងចំណោមប្រភពសាច់ប្រាក់មួយចំនួន សម្រាប់គ្រួសារជាច្រើន។

១២. ផលប័ត្រនេះបានស្វែងរកការកែលម្អការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន នៅក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ។ អ្នកធ្វើការផ្សព្វផ្សាយកសិកម្មឃុំដែលត្រូវបានជួលដោយគម្រោងទាំងនេះ បានបំពេញចន្លោះខ្វះខាតនៃចំនួនអ្នកធ្វើការផ្សព្វផ្សាយកសិកម្មក្នុងរដ្ឋាភិបាល។ គម្រោងទាំងនេះក៏បានគាំទ្រដល់កសិករដែលមានស្ថានភាពកម្រិតខ្ពស់ផងដែរ ដើម្បីឲ្យពួកគេអាចផ្តល់ការគាំទ្រ និងដំបូន្មាន

ដល់កសិករដទៃទៀត ប៉ុន្តែ ប្រសិទ្ធផលរបស់ពួកគេ មានកម្រិតខុសៗគ្នា។ ចំណុចសំខាន់ៗដែលត្រូវលើកឡើង គឺថា គម្រោងទាំងនេះ តាមរយៈបណ្តាញផ្តល់ទុនវិនិយោគ តាមរយៈរចនាសម្ព័ន្ធវិមជ្ឈការ បានផ្តល់ដល់មន្ទីរខេត្ត (កសិកម្ម កិច្ចការនារី អភិវឌ្ឍន៍ជនបទ) និងរដ្ឋបាលថ្នាក់ក្រោមជាតិ នូវឱកាសសម្រាប់ "ធ្វើការងារបណ្តើរ-រៀនសូត្របណ្តើរ"។ សរុបមក ការគាំទ្រដល់ការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធជនបទ បានសម្រេចគោលដៅរូបវន្ត និងបានរួមចំណែកដល់ដំណើរការវិមជ្ឈការ ប៉ុន្តែ ក៏នៅមានបញ្ហារៀបចំ/តាក់តែង និងគុណភាពនៃសំណង់ស៊ីវិល ផងដែរ (ឧ. ប្រព័ន្ធធារាសាស្ត្រ)។

**១៣. ប្រសិទ្ធភាព** ជាទូទៅ ផលប័ត្រឥណទាន អនុវត្តបានល្អ លើសូចនាករនៃប្រសិទ្ធភាព ពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌពេលវេលា និងការផ្តល់ថវិកា ប៉ុន្តែមិនល្អ លើការគ្រប់គ្រងគម្រោង និងលើដំណើរការអនុវត្តគម្រោង រួមទាំងប្រព័ន្ធលទ្ធកម្ម តាមដាន និងវាយតម្លៃ។ គម្រោងខ្លះ ដូចជា គម្រោងអភិវឌ្ឍន៍កសិករខ្នាតតូច និង កាត់បន្ថយភាពក្រីក្រនៅតំបន់បឹងទន្លេសាប (TSSD) និង កម្មវិធីសេវាកសិកម្មសម្រាប់ការច្នៃប្រឌិតថ្មីៗ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការផ្សព្វផ្សាយកសិកម្ម (ASPIRE) បានជួបនឹងផលលំបាកពីការចាប់ផ្តើមយឺតយ៉ាវ និងផលលំបាកក្នុងការអនុវត្ត។ ជាមួយនឹងករណីលើកលែងមួយចំនួនតូច អត្រាទាញចំណូលផ្ទៃក្នុងផ្នែកសេដ្ឋកិច្ចដែលត្រូវបានគេប៉ាន់ប្រមាណថាសម្រេចបាន គឺនៅស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន ប៉ុន្តែ មានកម្រិតទាបជាងការប៉ាន់ប្រមាណនៅអំឡុងពេលតាក់តែងគម្រោង និង ទាបជាងការប៉ាន់ប្រមាណឡើងវិញដែលបានរាយការណ៍នៅក្នុងរបាយការណ៍បញ្ចប់គម្រោង។

**១៤. ផលប៉ះពាល់លើភាពក្រីក្រនៅជនបទ:** ផលប័ត្រឥណទាន បានរួមចំណែកដល់ការបង្កើនប្រាក់ចំណូល និងទ្រព្យសម្បត្តិគ្រួសារ ជាពិសេស សម្រេចបានពីការកែលម្អផលិតភាព និងការធ្វើប្រពលវប្បកម្មកសិកម្ម និងក្នុងករណីខ្លះ សម្រេចបានលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ ទោះជាយ៉ាងណាក្តី ជាមួយនឹងឱកាសប្រាក់ចំណូលកើនឡើងក្នុងវិស័យមិនមែនកសិកម្ម ផលប៉ះពាល់នៃគម្រោង ក្នុងករណីនេះ ប្រហែលជាមិនមែនជាកត្តាសំខាន់ និងកត្តាកំណត់ ចំពោះកំណើនប្រាក់ចំណូលគ្រួសារសរុបរបស់អ្នកទទួលផលនោះឡើយ។ ដូចគ្នានេះដែរ ថ្វីបើវាមានការលំបាកក្នុងការប៉ាន់ស្មានពីវិសាលភាពនៃការរួមចំណែករបស់គម្រោង ដោយយោងទៅលើនិន្នាការថ្នាក់ជាតិនៃការកាត់បន្ថយភាពក្រីក្រ និងការកែលម្អសន្តិសុខស្បៀងគួរឲ្យកត់សំគាល់ គេអាចជឿទុកចិត្តបានយ៉ាងខ្ពស់ថា ផលប័ត្រឥណទាន បានរួមចំណែកដល់ការកែលម្អសន្តិសុខស្បៀង។ ទោះជាយ៉ាងណាក្តី ថ្វីបើ មានការបង្ហាញពីភាពវិជ្ជមាននេះក៏ដោយ កង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាចម្បងនៅក្នុងប្រទេស ហើយការចូលរួមចំណែករបស់គម្រោងក្នុងករណីនេះ មិនទាន់មានភស្តុតាងនៅឡើយ។

**១៥.** ទាក់ទងទៅនឹងធនធានមនុស្ស អ្នកទទួលផលជាច្រើនបានទទួលនូវជំនាញថ្មីៗ ហើយយ៉ាងហោចណាស់ បានអនុវត្តនូវជំនាញខ្លះដែលពួកគេបានរៀន ដូចជា ការអនុវត្តកំណែលម្អកសិកម្មដែលបានបង្រៀន ឬសកម្មភាពបង្កើតប្រាក់ចំណូលដែលមិនមែនជាដីធ្លី (ឧ. ការត្បាញកន្ទេល)។ ការបណ្តុះបណ្តាលលើប្រធានបទផ្សេងៗគ្នា ក៏បាននាំឱ្យមានការផ្លាស់ប្តូរឥរិយាបថក្នុងរបៀបខ្លះៗ ផងដែរ (ឧ. ជំនាញភាពជាអ្នកដឹកនាំ ការផ្តល់អាហាររូបត្ថម្ភដល់កុមារ)។ ផលប៉ះពាល់របស់គម្រោងទៅលើធនធានសង្គម និងការផ្តល់ភាព

អង់អាច ទទួលបានលទ្ធផលតិចតួច ប៉ុន្តែមានភស្តុតាងនៃករណីដែលគម្រោងបានគាំទ្រ ជួយសម្របសម្រួលបណ្តាញ និងការបង្កើតឡើងនូវអង្គការតាមជនបទ។

**១៦.** គម្រោងទាំងនេះ បានរួមចំណែកដល់ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងតំបន់របស់គម្រោង ប៉ុន្តែ លទ្ធផលនេះ មិនមានន័យថាមានភាពប្រសើរឡើងដោយចេរភាព នោះឡើយ។ ផលប័ត្រឥណទានរបស់ IFAD បានរួមចំណែកដល់ទិដ្ឋភាពខ្លះៗនៃការពង្រឹងគោលនយោបាយ និងស្ថាប័ន ដោយមានការគាំទ្រយ៉ាងច្រើន ពីដៃគូអភិវឌ្ឍន៍ដទៃទៀត ទាក់ទងនឹងវិស័យនានា ដូចជា ការលើកកម្ពស់វិធីសាស្ត្រដែលមានការចូលរួម និង វិធីសាស្ត្រផ្អែកលើតម្រូវការ និងសេវាកម្មផ្សព្វផ្សាយកសិកម្មចំរុះ ដោយមានការចូលរួមពីអ្នកផ្តល់សេវាឯកជន ព្រមទាំងការណែនាំអំពី "ស្ថាប័ន" ថ្មីៗ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម (ឧ. បុគ្គលិកសុខភាពសត្វតាមភូមិ) ។ ម្យ៉ាងទៀត សូម្បីតែអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាន ដូចជា បុគ្គលិកផ្សព្វផ្សាយកសិកម្មឃុំក៏ដោយ បច្ចុប្បន្ន ពួកគេគឺជាផ្នែកមួយនៃគោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់រាជរដ្ឋាភិបាល។ វត្តមានរបស់ពួកគេមានការពឹងអាស្រ័យយ៉ាងខ្លាំងទៅលើគម្រោងដែលឧបត្ថម្ភថវិកាដោយអ្នកផ្តល់ជំនួយ ហើយវត្តមានរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មទាំងនេះ មិនទាន់បានយកទៅអនុវត្តជាប្រព័ន្ធដែលមានលក្ខណៈជាស្ថាប័ននៅឡើយ។

**១៧. និរន្តរភាពនៃអត្ថប្រយោជន៍:** ផ្នែកជាច្រើននៃផលប័ត្រឥណទាន មានបញ្ហាប្រឈមផ្នែកនិរន្តភាព។ មនុស្សម្នាក់អាចជំទាស់ថា កសិករទំនងជាបន្តអនុវត្តបច្ចេកវិទ្យា និង ការអនុវត្តដែលមានការកែលម្អ ប្រសិនបើសហគ្រាសផ្តល់ចំណូលលើពលកម្មដែលមានស្ថានភាពខ្ពស់ជាង ឬ បើប្រៀបធៀបទៅនឹងឱកាសផ្សេងៗទៀត។ ក៏ប៉ុន្តែ ប្រសិនបើកសិករនៅបន្តអភិវឌ្ឍន៍ជំនាញ និងចំណេះដឹងរបស់ខ្លួនឲ្យទាន់សម័យ (ឧ. ពូជចំរុះថ្មី ការអនុវត្តការគ្រប់គ្រងជម្ងឺ ឬកត្តាចង្រៃ) កត្តានេះ នឹងតម្រូវឲ្យមានការពឹងផ្អែកយ៉ាងទូលំទូលាយលើការផ្តល់ប្រឹក្សាយោបល់ និងសេវាផ្សព្វផ្សាយកសិកម្ម ក៏ដូចជា សេវាបទបញ្ញត្តិមុខងារ ដែលសេវាទាំងនេះ មិនទាន់ត្រូវបានបង្កើតឡើងក្នុងលក្ខណៈល្អប្រសើរនៅឡើយ។ ថវិកាសាធារណៈសម្រាប់សេវាគាំទ្រ និងផ្សព្វផ្សាយកសិកម្ម មានតែមួយចំណែកតូចនៃធនធាន ដែលបានផ្តល់ដោយគម្រោងនានា ក្នុងអំឡុងពេលនៃការអនុវត្តគម្រោងប៉ុណ្ណោះ។

**១៨.** គម្រោងទាំងអស់ បានគាំទ្រដល់ការបង្កើតក្រុមអ្នកទទួលផល ភាគច្រើន គឺដើម្បីក្លាយជាអ្នកទទួលផលពីការបណ្តុះបណ្តាល សេវាផ្សព្វផ្សាយកសិកម្ម និងមូលនិធិ GRF។ ការរៀបចំគម្រោង គឺមានភាពមិនច្បាស់លាស់ ថាតើក្រុមទាំងនោះ ជាយន្តការផ្តល់សេវាគម្រោងបណ្តោះអាសន្ន ឬក៏ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ និងការផ្តល់ភាពអង់អាចរយៈពេលវែង។ ក្រុម GRF រាប់ពាន់ ត្រូវបានបង្កើតឡើង ប៉ុន្តែ មានការយឺតយ៉ាវក្នុងការអនុវត្ត ដែលនាំឲ្យមានការគិតថា តើក្រុមទាំងនេះ អាចនឹងមាននិរន្តរភាពដែរ ឬយ៉ាងណា។ គម្រោងទាំងនោះ ទំនងជាបានយកចិត្តទុកដាក់បន្តិចបន្តួច ទៅលើការរៀបចំកសិករ ដើម្បីកែលម្អអំណាចតថ្លៃរបស់ពួកគេ ទល់នឹងតួអង្គទីផ្សារដទៃទៀត។ ករណីដោយឡែកគួរឱ្យកត់សម្គាល់មួយចំនួន គឺសហគមន៍កសិកម្មដែលបាន លេចឡើងពីគម្រោង RULIP (នៅខេត្តព្រះវិហារ) ក៏ដោយសារតែឱកាសទីផ្សារបានកើតឡើងសម្រាប់អង្ករសរីរាង្គ។

១៩. ទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលត្រូវបានគាំទ្រក្នុងគម្រោងដែលបានបិទបញ្ចប់ចំនួនពីរមានការព្រួយបារម្ភមួយចំនួនអំពីនិរន្តរភាពនៃសមិទ្ធផលនេះ ដោយសារតែថវិកាមានកម្រិតសម្រាប់ប្រតិបត្តិការ និងការថែទាំ (ប្រព័ន្ធធារាសាស្ត្រ និងផ្លូវថ្នល់) ឬការរៀបចំគម្រោងមិនបានល្អ ពីដើមទី (ប្រព័ន្ធធារាសាស្ត្រ)។

**២០. ការច្នៃប្រឌិតថ្មី:** ផលប័ត្រឥណទាន បាននាំមកនូវការច្នៃប្រឌិតថ្មីមួយចំនួន ដែលជារឿយៗ ត្រូវបានណែនាំដោយវិស័យឯកជន/អង្គការក្រៅរដ្ឋាភិបាល ទៅក្នុងប្រព័ន្ធរដ្ឋាភិបាល និងការច្នៃប្រឌិតថ្មីៗ ពីគម្រោងដំបូងៗ ត្រូវបានចម្លងតាមគ្នាជាបន្តបន្ទាប់ ក្នុងគម្រោងក្រោយៗ។ មុនពេលមានផលប័ត្រឥណទាន គម្រោងគាំទ្រកសិកម្មដល់សិលា (ADESS) ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៩ ដែលមិនមែនជាផ្នែកមួយ នៃការវាយតម្លៃផលប័ត្ររបស់ CSPE ដែលបានផ្តល់ជំនួយដល់កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ (D&D) និងអភិបាលកិច្ចមូលដ្ឋានសម្រាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទដើម្បីជួយដល់ជនក្រីក្រ ដែលជាគម្រោងខ្នាតធំមួយទទួលបានការឧបត្ថម្ភមូលនិធិពីខាងក្រៅ ហើយខ្សែបន្ទាត់នៃការគាំទ្រនេះត្រូវបានចម្លង និង រក្សាទុកសម្រាប់អនុវត្តក្នុងគម្រោងបន្តបន្ទាប់ទៀត។

២១. ការច្នៃប្រឌិតថ្មីមួយដែលបានឡើងពីគម្រោងអភិវឌ្ឍជនបទតាមសហគមន៍នៅខេត្តកំពង់ធំ និងកំពត (CBRDP ឆ្នាំ២០០១-២០០៩) ដោយមានការរួមចំណែកពីដៃគូអភិវឌ្ឍន៍ដទៃទៀតផងដែរ ពាក់ព័ន្ធនឹងវិធីសាស្ត្រកំណត់គោលដៅភាពក្រីក្រ តាមរយៈការធ្វើចំណាត់ថ្នាក់នៃទ្រព្យសម្បត្តិដោយមានការចូលរួម ដែលបច្ចុប្បន្ន បានក្លាយទៅជាយុទ្ធសាស្ត្រស្ថាប័ន ដែលជាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាល។ គោលបំណងដើម្បីអនុវត្តវិធីសាស្ត្រដែលមានការចូលរួម ប្រកបដោយភាពច្នៃប្រឌិតថ្មី ចំពោះការបណ្តុះបណ្តាល និងសេវាផ្សព្វផ្សាយកសិកម្ម មិនទាន់បានសម្រេចពេញលេញនៅឡើយទេ។ ប៉ុន្តែការកែលម្អ និងការច្នៃប្រឌិតថ្មីមួយចំនួន អាចត្រូវបានគេមើលឃើញនៅក្នុងគម្រោងនាពេលថ្មីៗនេះ។ សមិទ្ធផលទាំងនេះរួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែង ក្នុងកែសម្រួលការបណ្តុះបណ្តាលដែលតម្រង់ទិសទៅរកជនជាតិដើម និងជនជាតិភាគតិច និងវគ្គបណ្តុះបណ្តាលផ្តោតលើគោលដៅបន្ថែមទៀត តាមរយៈ "ក្រុមមានផលប្រយោជន៍រួម" ការបណ្តុះបណ្តាល ជាលក្ខណៈពីកសិករមួយទៅកសិករមួយ និង គំរូនៃភាពជាដៃគូរវាងរដ្ឋនិងឯកជនក្នុងការផ្តល់សេវាកសិកម្ម តាមរយៈអ្នកជំនាញអាជីវកម្មកសិដ្ឋានដែលនឹងលក់ផលិតផលកសិកម្ម ផ្តល់សេវាប្រឹក្សាយោបល់ និងទិញផលិតផលកសិកម្ម (គម្រោងអភិវឌ្ឍន៍កសិកម្ម និង ការពង្រឹងអំណាចសេដ្ឋកិច្ច PADEE) ។ លើសពីនេះទៅទៀត នៅក្នុងគម្រោងនាពេលថ្មីៗនេះ សកម្មភាពដែលផ្តោតលើអាហាររូបត្ថម្ភមួយចំនួន ក៏ត្រូវបានគេណែនាំឱ្យទទួលបានការបណ្តុះបណ្តាលដែលមានផលប្រយោជន៍ ជាពិសេសសម្រាប់មាតារបស់ទារក រួមទាំងវិធីសាស្ត្រច្នៃប្រឌិតថ្មីៗមួយចំនួន ដូចជា "ការប្រកួតប្រជែងចំអិនអាហារ" "មាតាដើងឯក" និង "ទីផ្សារសង្គមពីមាតាទៅមាតា" ។

**២២. ការពង្រីកវិសាលភាព:** ការពង្រីកវិសាលភាពលើសពីផលប័ត្រឥណទានរបស់ IFAD មានកម្រិតតិចតួច។ ការច្នៃប្រឌិតថ្មីៗជាច្រើន ត្រូវបានចម្លងពីមួយទៅមួយក្នុងគម្រោងទាំងឡាយដែលគាំទ្រដោយ IFAD ទោះបីជាក្នុងស្ថានភាពមានការកែប្រែខ្លះ ក៏ដោយ។ មានតែករណីមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានពង្រីកវិសាលភាព និងបានអនុវត្តយ៉ាងទូលំទូលាយ ដូចជា បុគ្គលិកសុខភាពសត្វភូមិ។ ទោះបីជាយ៉ាងណាក្តី វាអាចទៅរួចដែលថា ការរៀបចំតាក់តែង និងការខិតខំប្រឹងប្រែងរបស់ផលប័ត្រឥណទានរបស់ IFAD ចាប់

តាំងពីឆ្នាំ១៩៩៦ ដោយរួមជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍន៍ដទៃទៀតទៅ បានរួមចំណែកដល់ទិសដៅសំខាន់ពីរនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការផ្សព្វផ្សាយកសិកម្មៈ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយផ្អែកលើតម្រូវការ និងដំណោះស្រាយពហុវិស័យ (រួមមាន រដ្ឋាភិបាលមានកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសហគ្រាសឯកជន ដើម្បីផ្តល់សេវា)។ ប្រសិនបើត្រូវបានអនុវត្ត វានឹងតំណាងឱ្យការពង្រីកវិសាលភាពយ៉ាងធំធេងមួយ ដែលនាពេលអនាគត អាចនឹងត្រូវបានគេទទួលស្គាល់ចំពោះសកម្មភាពកន្លងមករបស់ IFAD និងដៃគូអភិវឌ្ឍន៍ដទៃទៀត។

**២៣.** ជាទូទៅ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃមិនគ្រប់គ្រាន់ (M&E) និងការគ្រប់គ្រងចំណេះដឹងបានរារាំងសក្តានុពលសម្រាប់ការពង្រីកវិសាលភាព ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នាពេលថ្មីៗនេះ ត្រូវបានធ្វើឡើង តាមរយៈក្រុមអ្នកគ្រប់គ្រងកម្មវិធីប្រចាំប្រទេស ដើម្បីកែលម្អទិដ្ឋភាពទាំងនេះ។

**២៤. សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីៈ** កំណត់ត្រាស្តីពីការគាំទ្រគម្រោង និងការចូលរួមចំណែកនៅក្នុងវិស័យនេះ ជាទូទៅ មានភាពខ្លាំងក្លាចំពោះផលប័ត្រឥណទាន។ កិច្ចសហការរវាងក្រសួងកិច្ចការនារី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា មន្ទីរថ្នាក់ខេត្តរបស់ពួកគេរៀងៗខ្លួន មានលក្ខណៈល្អ ដែលបានរួមចំណែកដល់សមិទ្ធផលនានាក្នុងវិស័យនេះ។ ការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ គឺជាផ្នែកមួយនៃការរៀបចំតាក់តែងគម្រោងទូទាំងផលប័ត្រឥណទាន ដែលការព្រួយបារម្ភលើបញ្ហាយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងការកំណត់គោលដៅ ការបណ្តុះបណ្តាល សកម្មភាព ការកសាងសមត្ថភាព និងទិន្នន័យដែលបែងចែកទៅតាមភេទ។ មានកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាបយេនឌ័ររួមគ្នា ទូទាំងគម្រោង និងនៅកម្រិតផ្សេងៗគ្នា ដូចជា នៅរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អ្នកផ្តល់សេវា និងក្រុមអ្នកទទួលផល។ ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពដែលគាំទ្រដោយគម្រោង មានកំរិតខ្ពស់ ទោះបីជាផ្នែកខ្លះអាចត្រូវបានពន្យល់ដោយមូលហេតុនៃបញ្ហាបរិបទខ្លះក៏ដោយ (ឧ. ការធ្វើចំណាកស្រុក)។

**២៥.** ការយកចិត្តទុកដាក់ជាប់ជានិច្ចរបស់ផលប័ត្រឥណទាន ចំពោះបញ្ហាយេនឌ័រ បានរួមចំណែកបង្កើនការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ។ តាមរយៈគម្រោងហិរញ្ញប្បទានរបស់ IFAD ដែលផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងក្រុម ស្ត្រីបានទទួលនូវបទពិសោធន៍ និងការចូលរួមសកម្មភាពជាមួយក្រុម និងនៅក្នុងវេទិកាសាធារណៈ។ គម្រោងទាំងនេះ ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយជនបង្គោលរបស់ក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រី និងកុមារ ដោយផ្តល់ឱ្យពួកគេនូវការបណ្តុះបណ្តាលដើម្បីបំពាក់ឱ្យពួកគេនូវលទ្ធភាពកាន់តែប្រសើរឡើងដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកយេនឌ័រ និងការតាមដានសកម្មភាពគម្រោងពីទស្សនវិស័យយេនឌ័រនៅក្នុងតំបន់របស់ពួកគេ។ គម្រោងទាំងនេះ បានគាំទ្រដល់លទ្ធភាពទទួលបានឱកាសសេដ្ឋកិច្ចរបស់ស្ត្រី ដូចជា ការចិញ្ចឹមមាន់ ការដាំបន្លែ និងសកម្មភាពដែលមិនមែនជាដីធ្លី ដូចជា ការផលិតពោត សណ្តែក និងការត្បាញកន្ទេល និងកន្ត្រក ជាដើម។

**២៦. ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានៈ** ផលប៉ះពាល់អវិជ្ជមានដ៏មានសក្តានុពលទៅលើបរិស្ថាន ពីហិរញ្ញប្បទានរបស់ IFAD សម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជនបទ (ឧ. ការស្តារឡើងវិញ និងការសាងសង់ភូមិដ្ឋានតូចៗ និងរចនាសម្ព័ន្ធកសិកម្មមួយចំនួន ដូចជា ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ក្នុងភូមិ ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធបង្ហូរទឹក) មានការធ្វេសប្រហែស។ គម្រោងជាច្រើន បានគាំទ្រដល់ផលិតកម្មសរីរាង្គ ឬ

ផលិតកម្មជាមួយការអនុវត្តកសិកម្មមានលក្ខណៈវិជ្ជមាន។ តែការគាំទ្រលើការគ្រប់គ្រងធនធានធម្មជាតិ (ឧ. ធនធានព្រៃឈើ និងជលផល ឬបរិស្ថានដែលមានភាពផុយស្រួយ) ជាទូទៅ មានកម្រិតតិចតួច ទោះបីជាការគាំទ្រទាំងនេះ មានសារៈសំខាន់ចំពោះជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី ក៏ដោយ។

**២៧. ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ:** ផលប័ត្រឥណទាន បានរួមចំណែកតិចតួចបំផុត ចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ចំពោះការកែលម្អភាពធន់ តាមរយៈការងារហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ទោះបីជាអន្តរាគមន៍មិនត្រូវបានកំណត់យ៉ាងច្បាស់លាស់ជាផ្នែកនៃយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក៏ដោយ។ នៅក្នុងផលប័ត្រឥណទានដែលកំពុងបន្តថ្មីៗនេះ មានអន្តរាគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុច្បាស់លាស់ - នៅក្នុង TSSD និងអន្តរាគមន៍មួយចំនួនទៀត នៅក្នុង PADEE ខណៈដែលការគាំទ្រសំខាន់ៗ ត្រូវបានរួមបញ្ចូលនៅក្នុង ASPIRE ។

## គ. ការអនុវត្តសកម្មភាពដែលមិនមែនជាកម្ចី

**២៨. ការគ្រប់គ្រងចំណេះដឹង:** ការគ្រប់គ្រងចំណេះដឹង - ផ្សាភ្ជាប់ទៅនឹងការពិគ្រោះយោបល់គោលនយោបាយគាំទ្រជនក្រីក្រដែលត្រូវបានគេកំណត់អត្តសញ្ញាណនៅក្នុង COSOP ឆ្នាំ២០០៨ និង២០១៣ ជាធាតុដ៏មានសារៈសំខាន់ដើម្បីកែលម្អប្រសិទ្ធផលនៃកម្មវិធីប្រចាំប្រទេស។ ការបង្កើនកិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើង ដើម្បីចាប់យក និងបង្កើតជាប្រព័ន្ធអំពីបទពិសោធន៍ និងមេរៀនរបស់គម្រោង និងចងក្រងជាកញ្ចប់ និងធ្វើការផ្សព្វផ្សាយព័ត៌មានទាំងនេះ។ របាយការណ៍គួរឲ្យកត់សំគាល់ និងសម្ភារៈទំនាក់ទំនងមួយចំនួនបានរៀបចំឲ្យមានឡើង ថ្វីបើការចូលទៅរក ឬទាញយកឯកសារទាំងនេះ មិនងាយស្រួលជានិច្ចជាកាលនោះក៏ដោយ។ កិច្ចខិតខំប្រឹងប្រែងសំខាន់ៗ កំពុងដំណើរការ ដើម្បីកែលម្អប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៅក្នុងគម្រោងវិនិយោគដែលផ្សាភ្ជាប់ទៅនឹងការពិនិត្យតាមដានវឌ្ឍនភាព COSOP ។ ការពិនិត្រឡើងវិញលើកម្មវិធីប្រចាំប្រទេស និងសកម្មភាពផ្សេងៗទៀត បានផ្តល់ឱកាសដល់អ្នកអនុវត្តន៍គម្រោង និងអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីធ្វើការចែករំលែកបទពិសោធន៍ និងភ្ជាប់បណ្តាញការងារទៅវិញទៅមក។ មានឧទាហរណ៍ខ្លះៗនៃជំនួយឥតសំណងដែលបានជួយសម្រួលដល់ការគ្រប់គ្រងចំណេះដឹង និងដែលរួមចំណែកដល់ការច្នៃប្រឌិតថ្មីៗ និងបានកែលម្អប្រសិទ្ធផលក្នុងគម្រោងវិនិយោគនានា ប៉ុន្តែ ថ្មីៗនេះ មានការយកចិត្តទុកដាក់កាន់តែច្រើនឡើងដើម្បីអភិវឌ្ឍន៍ទំនាក់ទំនងឲ្យកាន់តែរឹងមាំឡើងរវាងកម្មវិធីជំនួយប្រចាំតំបន់ និងផលប័ត្រឥណទានវិនិយោគ។

**២៩. ការកសាងភាពជាដៃគូ:** កិច្ចសហការរវាង IFAD និងភ្នាក់ងាររដ្ឋាភិបាលនានា ជាទូទៅ មានលក្ខណៈល្អប្រសើរ។ ឧទាហរណ៍ ពាក់ព័ន្ធទៅនឹងដំណើរការអភិវឌ្ឍ COSOP និងការពិនិត្យឡើងវិញលើកម្មវិធីប្រចាំប្រទេស ឬនៅក្នុងករណីដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្តល់ទីកន្លែងការិយាល័យសម្រាប់មន្ត្រីកម្មវិធីប្រចាំប្រទេសរបស់ IFAD នៅក្នុងអគាររបស់ក្រសួង រហូតដល់ទីតាំងការិយាល័យរបស់ IFAD សមស្របមួយ ត្រូវបានបង្កើតឡើង។ ។ មានការវាយតម្លៃខ្ពស់របស់រាជរដ្ឋាភិបាលចំពោះតួនាទី របស់ IFAD ក្នុងការគាំទ្រដល់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទដែលគាំទ្រដល់ជនក្រីក្រ ត្រូវបានបញ្ជាក់ ដោយសំណើរបស់រដ្ឋាភិបាលចំពោះ IFAD ថា "បានដើរតួនាទីសំខាន់ជាងមុន នៅកម្រិតគោលនយោបាយ

តាមរយៈក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក " និង " ពិចារណាលើលទ្ធភាព បង្កើតស្ថានបេសកកម្មប្រចាំប្រទេស នៅកម្ពុជា។ "

៣០. ក្រៅពីភ្នាក់ងាររបស់រដ្ឋាភិបាល យុទ្ធសាស្ត្រ និងវិធីសាស្ត្រសម្រាប់ការកសាងភាពជាដៃគូបានវិវត្ត និងមានភាពចម្រុះ ក្នុងការស្វែងរកឱកាសសម្រាប់សហហិរញ្ញប្បទាន និងការធ្វើជាដៃគូជាមួយអង្គការនានាដែលអាចបំពេញបន្ថែមលើចន្លោះខ្វះបទពិសោធន៍របស់ IFAD និងវត្តមានក្នុងគម្រោងវិនិយោគក្នុងដំណាក់កាលដំបូងៗ ដើម្បីលើកកម្ពស់ ជាមួយនឹងការរួមចំណែកយ៉ាងសំខាន់ដល់ខ្លឹមសារផ្នែកបច្ចេកទេស ភាពជាដៃគូយ៉ាងទូលំទូលាយទាំងក្នុង និងក្រៅផលប័ត្រវិនិយោគ។ នៅក្នុងផលប័ត្រវិនិយោគ ដៃគូនានា បានបំបែកជាច្រើនផ្នែក ពីភ្នាក់ងារជំនួយសហហិរញ្ញប្បទាន ទៅរួមបញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពដទៃទៀត។ ភាពជាដៃគូជាមួយអង្គការកសិករ និងអង្គការជនជាតិដើមភាគតិច គឺជាលក្ខណៈពិសេសដោយឡែកមួយ របស់ IFAD ហើយបានបង្កើតចេញនូវជំនួយប្រចាំតំបន់ និងគំនិតផ្តួចផ្តើមសាជីវកម្ម។

៣១. **ការចូលរួមគោលនយោបាយក្នុងប្រទេស:** បទពិសោធន៍លើគម្រោងវិនិយោគមួយចំនួន រួមជាមួយការគាំទ្រពីសំណាក់ម្ចាស់ជំនួយដទៃទៀត បានរួមចំណែកផ្តល់ព័ត៌មាន និងបង្កើតគោលនយោបាយផ្សព្វផ្សាយកសិកម្ម និងការបញ្ជ្រាបយេនឌ័រទៅក្នុងគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍជនបទ និងកសិកម្ម។ ការរួមចំណែករបស់ IFAD ដើម្បីគាំទ្រដល់ការចូលរួមរបស់អង្គការកសិករនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីកសិកម្មនិងទឹក ដែលអាចត្រូវបានចាត់ទុកថា ជារូបភាពចូលរួមក្នុងគោលនយោបាយដោយប្រយោល គឺជាសកម្មភាពដ៏មានតម្លៃ។ ប៉ុន្តែ ការគាំទ្រជាយុទ្ធសាស្ត្រ និងដោយមានរចនាសម្ព័ន្ធ ព្រមទាំងសកម្មភាពសម្រាប់ការចូលរួមក្នុងគោលនយោបាយលើសពីកម្រិតគម្រោង នៅមានកម្រិតកំណត់ ដោយសារតែខ្វះធនធាន មនុស្សនៅការិយាល័យប្រចាំប្រទេសរបស់ IFAD និង ការប្រើប្រាស់ជំនួយឥតសំណងជាយុទ្ធសាស្ត្រ និង មានលក្ខណៈសកម្មតិចតួច។

## ឃ. ការអនុវត្តរបស់ដៃគូ

៣២. IFAD: ជាទូទៅ IFAD បានវិនិយោគធនធាន និងពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំតាក់តែងការត្រួតពិនិត្យ និងការគាំទ្រការអនុវត្តគម្រោងសម្រាប់ផលប័ត្រ និងបានបង្ហាញនូវឆន្ទៈរបស់ខ្លួនជាប្រចាំក្នុងការគាំទ្រដល់បញ្ហាអនុវត្តន៍ដែលបានកើតឡើង។ មូលនិធិនេះ ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតផងដែរ (ឧ. សហហិរញ្ញប្បទាន) ក្នុងការគាំទ្ររៀបចំ និងការអនុវត្តន៍គម្រោង។ ម៉្យាងទៀត ការវិនិយោគគ្រប់គ្រាន់ និងបំណងល្អ មិនតែងតែនាំមកនូវការរៀបចំគម្រោងបានល្អ និងការគាំទ្រការអនុវត្តប្រកបដោយប្រសិទ្ធភាពនោះទេ។ មានចំណុចខ្សោយមួយចំនួន និង ការពន្យាពេលក្នុងការដាក់បញ្ចូលមេរៀនដែលបានរៀនសូត្រ ការចាប់ឲ្យទាន់ជាមួយនឹងការផ្លាស់ប្តូរបរិបទឆាប់រហ័ស ព្រមទាំងការរកឃើញ និងការធ្វើសកម្មភាពលើការរៀបចំ និងបញ្ហាអនុវត្តន៍។ រហូតដល់ចុងឆ្នាំ២០០០ ផលប័ត្រឥណទានរបស់ IFAD នៅតែមានស្ថេរភាព និងបានអនុវត្តសារចុះសារឡើងនូវវិធីសាស្ត្រ និងគំរូដូចគ្នា ឬ ស្រដៀងគ្នានៅតាមតំបន់ផ្សេងៗគ្នា។ វត្តមានប្រចាំប្រទេសដែលមានកម្រិតតិចតួច បានរារាំង IFAD ពីការចូលរួមក្នុងសកម្មភាពដែលមិនមែនជាកម្ចី ឲ្យបានពេញលេញនិងគត់មុតល្អ។

**៣៣. រដ្ឋាភិបាលៈ** ការអនុវត្តរបស់រដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងគម្រោងជាទូទៅ ការសម្របសម្រួល និងការត្រួតពិនិត្យ ត្រូវបានប្របាច់បញ្ចូលគ្នា។ ទិដ្ឋភាពខ្លះៗនៃប្រសិទ្ធភាព ដែលទទួលរងឥទ្ធិពលពីការអនុវត្តរបស់រដ្ឋាភិបាល មានភាពវិជ្ជមាន (ឧ. ភាពទាន់ពេលវេលា ការបញ្ចេញសាច់ប្រាក់ ការចំណាយលើការគ្រប់គ្រង)។ ម៉្យាងទៀត ការអនុវត្តការគ្រប់គ្រងគម្រោង នៅមានកម្រិតប្រែប្រួល។ ដោយហេតុថា អង្គភាពគាំទ្រគម្រោងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានវត្តមានចាប់តាំងពី ADESS ហើយមានបទពិសោធន៍កើនឡើងក្នុងការគ្រប់គ្រងគម្រោងហិរញ្ញប្បទានរបស់ IFAD និង គម្រោងរបស់ម្ចាស់ជំនួយដទៃទៀត ការផ្តល់ពិន្ទុកន្លងមកលើការគ្រប់គ្រងគម្រោង មានលក្ខណៈទាបជាងអ្វីដែលគេរំពឹងទុក។ ការពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងការធ្វើលទ្ធកម្ម គឺស្ថិតក្នុងចំណោមផ្នែកដែលខ្សោយជាងគេបំផុត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសហការជាទូទៅ នៅដំណាក់កាលផ្សេងៗគ្នានៃគម្រោង។

**៣៤.** ការសម្របសម្រួលអន្តរស្ថាប័ននៅក្នុងជួររដ្ឋាភិបាល បានជួបប្រទះបញ្ហាប្រឈមជាច្រើន ប៉ុន្តែកិច្ចសហការ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងកិច្ចការនារី និងរវាងមន្ទីរខេត្តនីមួយៗរបស់ពួកគេ បានដំណើរការទៅយ៉ាងល្អ ដែលបានរួមចំណែកដល់ការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងនានាប្រកបដោយប្រសិទ្ធភាព។

## ខ. ការអនុវត្តយុទ្ធសាស្ត្រកម្មវិធីប្រចាំប្រទេស

**៣៥. ភាពពាក់ព័ន្ធៈ** ការយកចិត្តទុកដាក់ជាទូទៅ លើការអភិវឌ្ឍកសិកម្ម និងជួយជនក្រីក្រនៅតាមជនបទ (ជាមួយនឹងការផ្តោតយកចិត្តទុកដាក់បន្ថែមទៅលើផលិតកម្មក្នុងឆ្នាំដំបូងៗ) ត្រូវបានបន្សុីគ្នាជាមួយនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលមួយចំនួន។ នៅពេលចាប់ផ្តើម នៅក្នុងប្រទេសមួយដែលមានម្ចាស់ជំនួយច្រើន IFAD ត្រូវស្វែងរកកាលានុវត្តភាព និង លំហរមួយដើម្បីចាក់បំពេញ និង ចាប់ដៃគូ។ បន្ទាប់មក ចាប់តាំងពីគម្រោងទី២ (ADESS) IFAD បានបន្តការយកចិត្តទុកដាក់ជាប្រចាំ និងវិធីសាស្ត្រក្នុងការគាំទ្រដល់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការវិនិយោគក្នុងរចនាសម្ព័ន្ធវិមជ្ឈការ និងសេវាកម្មកសិកម្មដែលផ្អែកលើតម្រូវការ ខណៈដែលជម្រើសអំពីដៃគូ និងតំបន់គោលដៅរបស់គម្រោង ទំនងជាត្រូវបានសម្រេចតាមឱកាសដែលកំពុងកើតឡើង។

**៣៦.** បន្ទាប់ពីប្រតិបត្តិការអស់រយៈពេលមួយទសវត្សរ៍ ជាមួយនឹងគម្រោងស្រដៀងគ្នានៅក្នុងតំបន់ផ្សេងៗទៀត ឱកាសដើម្បីឆ្លុះបញ្ចាំងយ៉ាងសំខាន់លើទិសដៅយុទ្ធសាស្ត្រនាពេលអនាគត សម្រាប់ COSOP ឆ្នាំ ២០០៨ ថ្មី ត្រូវបានខកខាន។ យុទ្ធសាស្ត្រឆ្នាំ២០០៨ ខ្វះភាពច្បាស់លាស់ និងខ្វះទិសដៅជាយុទ្ធសាស្ត្រ ។ ដំណើរការបង្កើត COSOP ឆ្នាំ២០១៣ ត្រូវបានរៀបចំឡើង និងមានការពិគ្រោះយោបល់ខ្ពស់យ៉ាងទូលំទូលាយ ហើយឯកសារនេះ មានលក្ខណៈវិភាគបន្ថែម ទោះបីជាមានភាពមិនស៊ីគ្នាខ្លះៗក៏ដោយ ឧទាហរណ៍ដូចជា ការផ្តោតលើតំបន់ភូមិសាស្ត្រ។

**៣៧. ប្រសិទ្ធផលៈ** គោលបំណងយុទ្ធសាស្ត្រ និង/ឬ សូចនាករនានាដែលបានបង្កើតឡើងមិនត្រឹមត្រូវល្អ នៅក្នុង COSOP បានធ្វើឱ្យពិបាក និងមិនមានអត្ថន័យ ដើម្បីវាយតម្លៃសមិទ្ធិផលសម្រេចបាន ធៀបនឹងគោលបំណង/សូចនាករទាំងនោះ។ ដោយផ្អែកលើចេតនានៃគោលបំណងយុទ្ធសាស្ត្រ តំបន់ដែលកម្មវិធីប្រចាំប្រទេសរបស់ IFAD បានធ្វើការរួមចំណែកពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រជាប្រវត្តិសាស្ត្រ រួមមានៈ ការ

បង្កើនផលិតភាពកសិកម្ម (ថ្វីបើមិនទាន់មានកម្រិតល្អប្រសើរខ្លាំងក៏ដោយ) ។ ដំណើរការវិមជ្ឈការ និង វិសហមជ្ឈការ ជាពិសេសទាក់ទងនឹងគំនិតផ្តួចផ្តើមផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទ និង សមភាពយេនឌ័រ ព្រមទាំងការផ្តល់ភាពអង់អាចដល់ស្ត្រី។ ផ្នែកខ្លះនៃផលប័ត្រឥណទាន ក៏បានរួមចំណែកផងដែរដល់ការទទួលបានទីផ្សារ និងសេវាកម្មនានា តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ។ លទ្ធភាពទទួលបានសេវាកែលំអផ្នែកផ្សព្វផ្សាយកសិកម្ម បានកើតឡើងនៅក្នុងរង្វង់ខួបរបស់គម្រោង ប៉ុន្តែមានភស្តុតាងតិចតួចណាស់ដែលបង្ហាញពីការដាក់បញ្ចូលទៅក្នុងស្ថាប័ន និងនិរន្តរភាព។

## ច. សេចក្តីសន្និដ្ឋាន

**៣៨.** ក្នុងបរិបទនៃបរិយាកាសរបស់ប្រទេសមួយ និងបរិបទជនបទដែលមានការវិវត្តយ៉ាងឆាប់រហ័ស កម្មវិធីប្រចាំប្រទេសនេះ បានផ្តល់នូវការរួមចំណែកក្នុងទិដ្ឋភាពសំខាន់ៗមួយចំនួននៃការផ្លាស់ប្តូរនៅតាមទីជនបទ។ ទាំងនេះ រួមមាន ការគាំទ្រដល់ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ជាអ្នកផ្តល់ហិរញ្ញប្បទានដ៏សំខាន់មួយជាលើកដំបូង ដែលបានភ្ជាប់បណ្តាញវិនិយោគទុនតាមរយៈរចនាសម្ព័ន្ធវិមជ្ឈការ និងក្របខ័ណ្ឌ ដែលកំពុងរីកចម្រើន ក៏ដូចជាសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅតាមជនបទ។ ផលប័ត្រឥណទាន ក៏បានរួមចំណែកដល់ការបង្កើនផលិតភាពកសិកម្មរបស់គ្រួសារក្រីក្រនៅតាមជនបទ ប៉ុន្តែអត្រានៃការទទួលយកមកអនុវត្ត សម្រាប់បច្ចេកវិទ្យាដែលបានកែលម្អ អាចសម្រេចបានខ្ពស់ ប្រសិនបើភាពទន់ខ្សោយមួយចំនួន (ឧ. ដូចជា វិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម និងវិធីសាស្ត្របណ្តុះបណ្តាល) ត្រូវបានដោះស្រាយ និង ឧបសគ្គផ្សេងៗទៀត (ឧ. កង្វះពលកម្ម និងមធ្យោបាយផលិតកម្មផ្សេងៗ) ត្រូវបានគេពិចារណា និងឆ្លើយតបបានសមស្រប។

**៣៩.** បន្ទាប់ពីមានគម្រោងស្រដៀងគ្នាជាបន្តបន្ទាប់ យុទ្ធសាស្ត្រ និងការរៀបចំតាក់តែងគម្រោងរបស់ IFAD សម្រាប់គម្រោងដែលខ្លួនគាំទ្រ បានធ្វើការផ្លាស់ប្តូរទៅតាមការប្រែប្រួលនៃបរិបទ ប៉ុន្តែជាមួយនឹងពេលវេលាយឺតយ៉ាវ និងមិនគ្រប់គ្រាន់។ ផលប័ត្រនេះ នៅតែមានស្ថេរភាពយ៉ាងទូលំទូលាយ រហូតមកដល់ឆ្នាំ២០១០ ថ្វីបើបរិយាកាសនៅតាមជនបទមានការវិវត្ត ជាមួយនឹងការអនុវត្តដដែលៗនៃវិធីសាស្ត្រស្រដៀងគ្នាជាច្រើន (ការកំណត់គោលដៅ ការបង្កើតក្រុម ការបណ្តុះបណ្តាលកសិកម្ម និងសេវាផ្សព្វផ្សាយកសិកម្មដែលបានរួមបញ្ចូលគ្នាជាមួយមូលនិធិ GRF) នៅក្នុងតំបន់ភូមិសាស្ត្រផ្សេងៗគ្នា។ មានតែចន្លោះពីឆ្នាំ ២០១០-២០១១ ប៉ុណ្ណោះដែលគម្រោងនានា បានចាប់ផ្តើមអនុវត្តវិធីសាស្ត្រតម្រង់ទិសទៅរកទីផ្សារ ដោយទទួលបានលទ្ធផលលើកទឹកចិត្តមួយចំនួន។

**៤០.** ផលប័ត្រឥណទាន មិនបានផ្តល់តម្លៃទាំងស្រុងលើសញ្ញាណនៃឱកាសរកចំណូលមិនមែនជាកសិកម្ម ដែលបានកើនឡើង និងកង្វះពលកម្មសម្រាប់គ្រួសារជនបទឡើយ។ ឧទាហរណ៍ គម្រោង នៅតែបានបន្តផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាដែលប្រើប្រាស់កម្លាំងពលកម្មច្រើន។ គម្រោងថ្មីៗ បានចាប់ផ្តើមគិតគូរពីគោលគំនិតនៃ "ផលកម្រៃសម្រាប់ពលកម្ម" ជំនួសឱ្យផលិតភាពដីធ្លី ប៉ុន្តែនៅតែសន្មតថា គ្រួសារជនបទចាត់ទុកវិស័យកសិកម្ម ជាវិស័យបង្កើតប្រាក់ចំណូលសំខាន់តែមួយគត់ ដោយមិនទទួលស្គាល់គ្រប់គ្រាន់ថា

គ្រួសារទាំងនេះ នឹងស្វែងរកផលចំណេញអតិបរមា ដល់ពលកម្មរបស់សមាជិកគ្រួសារនៅក្នុងកសិដ្ឋាន ឬនៅក្រៅកសិដ្ឋាន ឬនៅខាងក្រៅភូមិឡើយ។

៤១. ទោះបីជានៅលើទំហំមួយដែលមានកម្រិតក៏ដោយ ការគាំទ្រដល់គ្រួសារក្រីក្រដើម្បីចូលរួមសកម្មភាពដែលមិនផ្អែកលើដីធ្លី ឬផលិតកម្មដែលមានតម្លៃខ្ពស់ បានទទួលលទ្ធផលវិជ្ជមានមួយចំនួន រួមទាំងការចិញ្ចឹមមាន់ និងសិប្បកម្មផលិតដោយដៃ។ ទទួលបានលទ្ធផលជាពិសេសគឺ សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រតាមជនបទនៅខេត្តព្រៃវែង និង ស្វាយរៀង រួមបញ្ចូលទាំងការគាំទ្រតិចតួចសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីជួយយុវជនឱ្យចាកចេញពីវិស័យកសិកម្ម។

៤២. ការគាំដល់សេវាផ្សព្វផ្សាយកសិកម្មផ្អែកលើតម្រូវការ បានដំណើរការស្របគ្នាតាមរយៈផលប័ត្រឥណទានជាមួយនឹងការទទួលបានលទ្ធផលចំរុះ។ គម្រោងទាំងនេះ មាននិន្នាការផ្តល់នូវបញ្ជីណែនាំបណ្តុះបណ្តាលស្តង់ដារមួយដល់ក្រុមកសិករ ដែលបានបង្កើតឡើង ប៉ុន្តែ ការកែលម្អបានធ្វើឡើងនៅក្នុងគម្រោងនាពេលថ្មីៗនេះ ដើម្បីធ្វើឱ្យការបណ្តុះបណ្តាលមានលក្ខណៈជាក់លាក់ជាងមុន និងឆ្លើយតបទៅនឹងតម្រូវការ។ វត្តមានភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដូចជាបុគ្គលិកផ្សព្វផ្សាយកសិកម្មឃុំ បានពឹងផ្អែក ភាគច្រើនទៅលើការផ្តល់ហិរញ្ញប្បទានរបស់ម្ចាស់ជំនួយ និងមិនត្រូវបានរៀបចំចូលក្នុងស្ថាប័ននោះទេ ទោះបីបច្ចុប្បន្ន ពួកគេជាផ្នែកមួយនៃគោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាល ក៏ដោយ។ ទោះជាយ៉ាងណាក្តី ផលប័ត្រឥណទានទាំងនេះ បានរួមចំណែកដល់ការណែនាំនៃការផ្តល់សេវាឯកជនដែលបានបង់ប្រាក់ ដោយអ្នកប្រើប្រាស់ ដូចជា បុគ្គលិកសុខភាពសត្វភូមិ ។ លើសពីនេះទៀត ការផ្តោតការយកចិត្តទុកដាក់ជាបន្ត បន្ទាប់នៃផលប័ត្រឥណទានរបស់ IFAD លើការធ្វើឱ្យប្រសើរឡើងស្តីពីការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ទំនងជាបានរួមចំណែកដល់ធាតុសំខាន់ៗ នៅក្នុងគោលនយោបាយផ្សព្វផ្សយកសិកម្មរបស់រាជរដ្ឋាភិបាលៈ នោះគឺ សេវាផ្សព្វផ្សាយកសិកម្មដែលឆ្លើយតបទៅនឹងតម្រូវការ និងមានលក្ខណៈចំរុះ។

៤៣. ការធ្វើពាណិជ្ជកម្ម និងកសិកម្មដែលត្រូវបានកែលម្អ និងមាននិរន្តរភាព មិនត្រឹមតែទាមទារនូវដំបូន្មានល្អៗអំពីការដាំដុះ និងការចិញ្ចឹមសត្វប៉ុណ្ណោះទេ ប៉ុន្តែក៏ទាមទារឲ្យមានសេវាច្បាប់ដែលមានប្រសិទ្ធភាពផងដែរ។ ក្នុងករណីអវត្តមាននៃការត្រួតពិនិត្យសមស្របទៅលើភូតគាមអនាម័យ និងបសុសត្វ ដំណាំទាំងមូល ឬឧស្សាហកម្មចិញ្ចឹមសត្វ និងការនាំចេញផលិតផលកសិកម្មដ៏សំខាន់ អាចមានហានិភ័យ។ គុណភាពនៃធាតុចូលកសិកម្ម (ឧ. គ្រាប់ពូជ ជី) និងផលិតផលកសិកម្ម និងផលិតផលកែច្នៃ តម្រូវឲ្យមានការគ្រប់គ្រង និងត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។ ការអភិវឌ្ឍខ្សែសង្វាក់តម្លៃ ដែលត្រូវបានលើកកំពស់ ក្រោមគម្រោងទីផ្សារចម្រុះដែលកំពុងបន្ថែមល្បឿននាពេលចុងក្រោយនេះសម្រាប់គម្រោងខ្នាតតូច (AIMS) នឹងត្រូវជួបការលំបាក ប្រសិនបើមិនទាន់មានសេវាច្បាប់គ្រប់គ្រាន់។

៤៤. អាចមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់ និងការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីគាំទ្រដល់ការផ្តល់ភាពអង់អាចដល់អ្នកទទួលផល និងអង្គការរបស់ពួកគេ។ ក្រុម GRF រាប់ពាន់នាក់ ត្រូវបានបង្កើតឡើង ប៉ុន្តែភាពយឺតយ៉ាវក្នុងការអនុវត្ត ត្រូវបានគេគិតអំពីវិធីថាត្រូវធ្វើដូចម្តេចដើម្បីឲ្យវាមាននិរន្តរភាព។ គម្រោងទាំងនេះ បានយកចិត្តទុកដាក់តិចតួចក្នុងការរៀបចំកសិករ ដើម្បីកែលម្អអំណាចចរចាររបស់ពួកគេ ទល់នឹងតួអង្គទីផ្សារដទៃទៀត ។ ករណីលើកលែងដ៏ល្អមួយចំនួន ដូចជាសហករណ៍កសិកម្មដែលបានកើតឡើងពី

គម្រោង RULIP (ក្នុងខេត្តព្រះវិហារ) ដែលជាផ្នែកមួយដ៏អស្ចារ្យដល់ឱកាសទីផ្សារថ្មីៗដែលកំពុងងើបឡើងសម្រាប់អង្គរសេរីវាង្គ។

**៤៥.** ភាពជាដៃគូយុទ្ធសាស្ត្រជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត នៅក្នុងគម្រោង បានរួមចំណែក ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផល និងបាននាំដល់ការបង្កើតការច្នៃប្រឌិតថ្មីៗ ជាពិសេសនៅក្នុងកម្មវិធី PADEE ដូចជាការបណ្តុះបណ្តាលកសិករដល់ក្រុមដែលមានផលប្រយោជន៍រួម វេទិកាពហុភាគីអ្នកពាក់ព័ន្ធ និង គម្រោងលាស់ថ្មី *(Lors Thmey)* ដែលជាសហគ្រាសសង្គមមួយ ជ្រើសរើស និងបណ្តុះបណ្តាលសហគ្រិនក្នុងស្រុកឱ្យក្លាយជាទីប្រឹក្សាអាជីវកម្មកសិដ្ឋាន ដែលបន្ទាប់មក ពួកគេនឹងបម្រើដល់សហគមន៍មូលដ្ឋានរបស់ពួកគេ តាមរយៈការលក់ផលិតផល និងសេវាកម្មកសិកម្ម។ ដោយសារមានបញ្ហាសមត្ថភាពក្នុងវិស័យសាធារណៈ ការធានាគុណភាពជំនួយបច្ចេកទេស បន្តជាយុទ្ធសាស្ត្រដែលមានសុពលភាព ដើម្បីកែលម្អប្រសិទ្ធផល និងផលប៉ះពាល់នៃកម្មវិធីប្រចាំប្រទេស។

**៤៦.** **កិច្ចខិតខំប្រឹងប្រែងបន្តដើម្បីកែលម្អការពិនិត្យតាមដាន** និងវាយតម្លៃ ផ្តល់ឱកាសដើម្បីបង្កើនការគ្រប់គ្រងចំណេះដឹង ការចូលរួមគោលនយោបាយ និងការពង្រីកវិសាលភាព។ ផ្អែកលើមូលដ្ឋាននេះ គម្រោង ASPIRE និង AIMS ជំនាន់ថ្មី អាចដើរតួនាទីជាយានដើម្បីសម្របសម្រួល និងគៀងគរការគាំទ្រ បន្ថែមពីដៃគូដទៃទៀតលើវិស័យសំខាន់ពីរក្នុងការអភិវឌ្ឍកសិកម្មខ្នាតតូច ដូចជា ការពង្រីកការផ្សព្វផ្សាយ កសិកម្ម និងការអភិវឌ្ឍខ្សែសង្វាក់តម្លៃកសិកម្មសម្រាប់គាំទ្រអ្នកក្រីក្រ។

**៤៧.** មានឧទាហរណ៍ល្អៗ មួយចំនួន នៃចំណងទាក់ទងជាមួយជំនួយឥតសំណង (ឧ. ROUTASIA [2] ជាមួយ PROCASUR, 4FGF[3] ជាមួយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់កសិកម្មតំបន់ត្រូពិច CIAT) ប៉ុន្តែក្នុងការធ្វើផែនការសកម្មភាពទូទៅ និងការប្រើប្រាស់ជំនួយឥតសំណង ត្រូវបានកម្រិតកំណត់។ ភាពជាដៃគូជាមួយអង្គការកសិករ និងអង្គការជនជាតិដើមភាគតិចដែលបានកើតឡើងពីគំនិតផ្តួចផ្តើមសារជីវកម្ម និងជំនួយក្នុងតំបន់ គឺជាទិដ្ឋភាពវិជ្ជមានមួយដែលទាក់ទងទៅនឹងអាណត្តិ និងភាពរឹងមាំរបស់ IFAD ។ មានការងារបន្ថែមជាច្រើនទៀត ដែលអាចធ្វើបាន ដើម្បីកែលម្អការសម្របសម្រួល និងការរួមបញ្ចូលគ្នារវាងជំនួយឥតសំណង និងគម្រោងវិនិយោគ។

## ច. អនុសាសន៍

**៤៨.** កថាខណ្ឌខាងក្រោម គឺជាអនុសាសន៍សំខាន់ៗសម្រាប់ធ្វីការពិចារណាដែលផ្តល់ឲ្យដោយ IFAD និងរាជរដ្ឋាភិបាលកម្ពុជា៖

**៤៩. អនុសាសន៍ទី១:** រៀបចំ និងប្រតិបត្តិការយុទ្ធសាស្ត្រសំខាន់ពីរសម្រាប់ផលប័ត្រឥណទានដែលគាំទ្រដល់: (១) ការធ្វើពាណិជ្ជកម្មកសិកម្មដោយផ្តោតលើកសិកម្មខ្នាតតូចមានលក្ខណៈជឿនលឿន និង (២) យុទ្ធសាស្ត្រដោះស្រាយរបស់គ្រួសារក្រីក្រ។ យុទ្ធសាស្ត្រទាំងនេះ គឺស្របទៅនឹងការតំរង់ទិសក្នុង COSOP ឆ្នាំ២០១៣ ដែលបានទទួលស្គាល់តម្រូវការសម្រាប់ "វិធីអភិវឌ្ឍន៍ និងរបៀបអន្តរាគមន៍ខុសៗគ្នា... សម្រាប់

[2] ការពង្រឹងទៅលើការចែករំលែកចំណេះដឹងស្តីពីបច្ចេកវិទ្យាច្នៃប្រឌិតថ្មី ដោយប្រើប្រាស់វិធីសាស្ត្រច្រកនៃការរៀនសូត្រក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក

[3] កម្មវិធីតភ្ជាប់ជីវភាពរស់នៅរបស់កសិករខ្នាតតូចក្រីក្រ ទៅនឹងទីផ្សារកសិឧស្សាហកម្មថ្មីដែលមិនបង្កឱ្យប៉ះពាល់បរិស្ថាន

ដោះស្រាយបញ្ហាអសន្តិសុខស្បៀង ជួយជនក្រីក្រនៅតាមជនបទដែលមានកម្រិតជីវភាពរស់នៅទន់ខ្សោយ និងគ្រួសារជនបទងាយរងគ្រោះដែលនៅពីលើបន្ទាត់ភាពក្រីក្របន្តិចបន្តួច"។ វាមានសារៈសំខាន់ណាស់ ក្នុងការបង្កើត និងធ្វើប្រតិបត្តិការយុទ្ធសាស្រ្តសមស្របទៅតាមទម្រង់នៃក្រុមគោលដៅ និងបរិបទជាក់លាក់ (ឧ. ទៅតាមសក្តានុពលកសិកម្ម និងឱកាសទីផ្សារនៅក្នុងតំបន់ភូមិសាស្រ្តជាក់លាក់) ។

**៥០.** សម្រាប់ប្រភេទទី១ ការគាំទ្រចំពោះផលិតកម្មបឋម អាចតម្រូវឲ្យមានជំនាញឯកទេស និងគុណភាពបច្ចេកទេសខ្ពស់ជាងអ្វីដែលបានផ្តល់ឲ្យដោយគម្រោងមកដល់ពេលបច្ចុប្បន្ន និងដែលបានកំណត់អាទិភាពដោយអ្នកបញ្ជាទិញ ផងដែរ ។ ខណៈពេលដែលការបណ្តុះបណ្តាលតាមក្រុម អាចមានជាប់ទាក់ទងទៅនឹងប្រធានបទខ្លះ ការណែនាំបច្ចេកទេសជាលក្ខណៈបុគ្គល ក៏ត្រូវការផងដែរ។ សេវាកម្មពិគ្រោះយោបល់ គួរតែត្រូវបានបំពេញបន្ថែមដោយការគាំទ្រដល់លទ្ធភាពទទួលបានមធ្យោបាយផលិតកម្ម រួមទាំងបច្ចេកវិជ្ជាសន្សំកម្លាំងពលកម្មសមស្រប (រួមទាំងគ្រឿងយន្ត) ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធទីផ្សារ។ ការពង្រឹងក្រុម/អង្គការកសិករ ដើម្បីសម្របសម្រួលទីផ្សារ គឺជាធាតុសំខាន់មួយ។ ខណៈពេលដែលវិធីសាស្រ្តខ្សែសង្វាក់តម្លៃអាចត្រូវបានបន្ត វាគួរតែមានភាពបត់បែន និងរស់រវើក ដើម្បីធ្វើអាជីវកម្មផ្លាស់ប្តូរឱកាសទីផ្សារ ជាជាងការធ្វើផែនការ ដែលមានចរឹកការិយាល័យធិបតេយ្យរយៈពេលវែង។

**៥១.** ការគាំទ្រដល់យុទ្ធសាស្រ្តដោះស្រាយសម្រាប់គ្រួសារក្រីក្រ អាចគ្របដណ្តប់លើសកម្មភាពផលិតកម្ម (ឧ. សកម្មភាពមិនផ្អែកលើដីធ្លីដែលអាចធ្វើទៅបាន ឧបករណ៍សន្សំសំចៃកម្លាំងពលកម្មសាមញ្ញៗ) ឬការបង្កើតឡើងនូវមធ្យោបាយទឹកស្អាតដែលនៅជិត ឬ ក្បែរផ្លូវក្នុងភូមិដែលងាយស្រួលប្រើប្រាស់។ សម្រាប់គ្រួសារក្រីក្រជាច្រើន ការយកចិត្តទុកដាក់ អាចលើសកម្មភាពកសិកម្មដែលបង្កើតប្រាក់ចំណូលដែលបំពេញបន្ថែមដល់សកម្មភាពមិនមែនកសិកម្ម ឬ ក្រៅកសិដ្ឋាន។ សម្រាប់យុវជននៃគ្រួសារក្រីក្រ ដែលបានសំរេចចិត្តចាកចេញពីភូមិ ភាពជាដៃគូរវាង IFAD និងរដ្ឋាភិបាល អាចស្វែងវិធីជួយពួកគេឱ្យរកប្រាក់ចំណូលបានប្រសើរជាងមុន តាមដែលអាចធ្វើទៅបាន ដូចជា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឬការផ្តល់ដំបូន្មានស្តីពីកិច្ចសន្យា និងរបៀបវិនិយោគប្រាក់ចំណូលដែលនៅសល់ពីការចាយ (ការផ្ញើប្រាក់) ត្រឡប់ទៅក្នុងភូមិវិញ។

**៥២.** យុទ្ធសាស្រ្តសំខាន់ទាំង២នេះ មិនគួរត្រូវបានអនុវត្តតាមរយៈការបំបែកគ្រួសារទៅក្នុងក្រុមផ្សេងៗគ្នា ដូចជាករណីដែលបានកើតឡើងនៅក្នុងគម្រោងមុនៗ នោះទេ។ ប៉ុន្តែតាមរយៈការកំណត់នូវបញ្ជីនៃប្រភេទជំនួយផ្សេងៗគ្នា អាចជួយតម្រង់ទិសទៅរកបរិបទនៅក្នុងតំបន់ភូមិសាស្រ្តខុសៗគ្នា។

**៥៣. អនុសាសន៍ទី២: តុល្យភាពនៃវិនិយោគលើធនធានមនុស្ស និងអង្គការជនបទដែលគាំទ្រដោយដៃគូយុទ្ធសាស្រ្តនានា មានផ្នែកសំខាន់ៗជាក់ស្តែងមួយចំនួន** ។ ការវិនិយោគនៅក្នុងទិដ្ឋភាព "ទន់": ដូចជាការអភិវឌ្ឍជំនាញ ការពង្រឹងស្ថាប័ន និងធនធានមនុស្ស នៅតែមានសារៈសំខាន់ ហើយកម្មវិធីនេះ គួរតែមានតុល្យភាពជាមួយនឹងការវិនិយោគក្នុងផ្នែកជាក់ស្តែងផ្សេងៗទៀត: ដូចជា ហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយគ្រប់គ្រងក្រោយការប្រមូលផល និងលទ្ធភាពទទួលបាន ហិរញ្ញប្បទានដែលអាចបង្កលក្ខណៈឱ្យអ្នកទទួលផលប្រើប្រាស់ជំនាញ និងចំណេះដឹងដែលពួកគេទទួលបាន ក្នុងការអនុវត្តជាក់ស្តែង។ ការវិនិយោគលើធនធានមនុស្ស មិនអាចគ្របដណ្តប់តែជំនាញផលិតកម្មនោះទេ។ ប៉ុន្តែ វាគ្របដណ្តប់ប្រធានបទទូលំទូលាយជាងនេះ ផងដែរ ដូចជា បញ្ហាយេនឌ័រ (ដូចដែលបានធ្វើរួចហើយ) អាហាររូបត្ថម្ភ អក្ខរកម្មមនុស្សពេញវ័យ

និងព័ត៌មានអំពីច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ។ នៅពេលជាមួយគ្នានេះដែរ វាគួរតែត្រូវបានទទួលស្គាល់ថា ទស្សនវិស័យយូរអង្វែង គឺតម្រូវឲ្យមានការវិនិយោគធនធានមនុស្ស/សង្គម និង ការផ្តល់ភាពអង់អាច។ ជាពិសេស ពាក់ព័ន្ធទៅនឹងប្រទេសកម្ពុជា ដោយសារប្រវត្តិសាស្ត្ររបស់ខ្លួន និងការអំពាវនាវ ឱ្យមានការប្រុងប្រយ័ត្នចំពោះការធ្វើសេចក្តីសម្រេចចិត្តវិនិយោគណាមួយ មិនគួរផ្អែកលើអត្រានៃការទទួលបានផលមកវិញនៃសេដ្ឋកិច្ច (IRR) ដែលជាប្រពៃណី តែមួយមុខប៉ុណ្ណោះទេ។

**៥៤.** ក្នុងការគាំទ្រដល់ការបង្កើតឡើង និងការពង្រឹងអង្គការនានារបស់ប្រជាជនដែលជាក្រុមជនគោលដៅ (ឧ. ក្រុមកសិករ) ការពិចារណាយ៉ាងប្រយ័ត្នប្រយែង គួរតែត្រូវបានផ្តល់ទៅលើគោលបំណងសំខាន់ៗ និងតួនាទីនៃប្រភេទអង្គការផ្សេងៗគ្នា (ជាមួយនឹងសំណុំរឿងនៃសមាជិកផ្សេងៗគ្នា) ព្រមទាំងយុទ្ធសាស្ត្រដកថយជាក់ស្តែងមួយ គួរតែត្រូវបានបង្កើតឡើងនៅក្នុងការរៀបចំតាក់តែងគម្រោងនានា។

**៥៥.** ដើម្បីធានានូវការគាំទ្រផ្នែកគុណភាព ជាពិសេសចំពោះទិដ្ឋភាព "ទន់" និងសម្រាប់ការច្នៃប្រឌិតថ្មីៗ ដោយសារសមត្ថភាពមានកម្រិត និងខ្សោយ នៅក្នុងវិស័យសាធារណៈ IFAD និងរដ្ឋាភិបាល គួរតែស្វែងរកឱកាសសម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រជាមួយស្ថាប័នដែលមានបទពិសោធន៍ផ្សេងៗទៀត ដែលអាចផ្តល់ជំនួយបច្ចេកទេសដ៏សំខាន់ៗ និងអាចគាំទ្រដល់រដ្ឋាភិបាល ដើម្បីអាចទទួលបាននូវសហហិរញ្ញប្បទាន ឬហិរញ្ញប្បទានដោយ IFAD ។

**៥៦. អនុសាសន៍ទី៣: បន្តការធ្វើផែនការយុទ្ធសាស្ត្របន្ថែម និងការប្រើជំនួយឥតសំណង និងហិរញ្ញប្បទានវិនិយោគ ដើម្បីបង្កើនភាពជាដៃគូកាន់តែស៊ីជម្រៅជាមួយអង្គការ/សមាគមកសិករ។** ការគាំទ្រដល់ និងភាពជាដៃគូជាមួយសមាគម/អង្គការកសិករ និងអង្គការជនជាតិដើមភាគតិច គួរតែត្រូវបានបន្ត និងពង្រឹង។ រហូតមកដល់ពេលនេះ គំនិតផ្តួចផ្តើមសាជីវកម្ម និងជំនួយឥតសំណងក្នុងតំបន់ បានសម្របសម្រួលចំណងទាក់ទងរវាងស្ថាប័នទាំងនេះនៅថ្នាក់ជាតិ និងកម្មវិធីប្រចាំប្រទេស។ វាតម្រូវឲ្យមានការរៀបចំផែនការយុទ្ធសាស្ត្របន្ថែមទៀត និងការប្រើប្រាស់ហិរញ្ញប្បទានរបស់ IFAD ទាំងជំនួយឥតសំណង និង ក្របខ័ណ្ឌគម្រោងវិនិយោគ ដើម្បីធ្វើការជាមួយអង្គការនៃប្រភេទផ្សេងៗគ្នា និងនៅកម្រិតខុសៗគ្នា។ ការកែលម្អភាពជាដៃគូ និងការពង្រឹងសមត្ថភាពរបស់ពួកគេ អាចរួមចំណែក: (១) ការផ្តល់ភាពអង់អាចដល់អង្គការទាំងនេះ និងសមាជិករបស់ពួកគេ (២) ការរៀបចំកម្មវិធីប្រចាំប្រទេស និងការតាក់តែងគម្រោងកាន់តែប្រសើរជាងមុន ដែលឆ្លុះបញ្ចាំងពីអាទិភាពរបស់ក្រុមគោលដៅ (៣) ធាតុចូលពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការគាំទ្រការអនុវត្តន៍ និង (៤) ឥទ្ធិពលទៅលើការចូលរួមគោលនយោបាយ តាមរយៈអង្គការដៃគូ ដែលតំណាងឱ្យសមាជិករបស់ពួកគេ និងក្រុមគោលដៅរបស់ IFAD ។

**៥៧. អនុសាសន៍ទី៤: ស្វែងរកនូវជម្រើសសម្រាប់ការគាំទ្រដល់សេវាច្បាប់ក្នុងវិស័យកសិកម្ម ក្នុងការអភិវឌ្ឍកម្មវិធីបន្តបន្ទាប់ទៀតនាពេលអនាគត។** វាទំនងជាវេទិកាសង្វាក់តម្លៃផ្សេងៗ នឹងត្រូវបានបង្កើតឡើងក្រោមគម្រោង AIMS នឹងចង្អុលបង្ហាញពីកង្វះខាតសេវាច្បាប់ (ដូចជា ការត្រួតពិនិត្យភូតគាមអនាម័យ និងបសុសត្វ ការត្រួតពិនិត្យគុណភាព និងស្តង់ដារ ការចេញវិញ្ញាបនប័ត្រ និងបញ្ហាសុវត្ថិភាពចំណីអាហារ) ជាឧបសគ្គមួយ ហើយសេវាច្បាប់ដែលមានលក្ខណៈចំពោះកិច្ចខ្លះ អាចទទួលបានការផ្តល់ហិរញ្ញប្បទាន។

ដោយសារចំណុចចាប់ផ្តើមនៅមានកម្រិតទាប គេតម្រូវឱ្យមាននូវវិធីសាស្ត្រកម្មវិធី និងជាប្រព័ន្ធកាន់តែច្រើនឡើង ដើម្បីគៀងគរហិរញ្ញប្បទានពីប្រភពផ្សេងៗ។

៥៨. **អនុសាសន៍ទី៥: IFAD ធ្វើការជាមួយរដ្ឋាភិបាលដើម្បីធ្វើយុទ្ធសាស្ត្រ និងសម្របសម្រួលការគៀងគរដៃគូដទៃទៀតឲ្យវិនិយោគលើកសិកម្មខ្នាតតូច។** បន្ថែមពីលើការគាំទ្រដ៏មានសក្តានុពលលើសេវាច្បាប់ (អនុសាសន៍លេខ៤) គម្រោង ASPIRE និង AIMS អាចដើរតួជាវេទិកាមួយ ដើម្បីនាំដៃគូដទៃទៀតមកវិនិយោគសម្រាប់វិស័យសំខាន់ៗចំនួនពីរ គឺ: ផ្នែកផ្សព្វផ្សាយកសិកម្ម និងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃកសិកម្មសម្រាប់ជួយជនក្រីក្រ។ ហិរញ្ញប្បទាននិងតួនាទីរបស់ IFAD គួរតែជួយលើកកំពស់ដល់ដៃគូ និងធនធានផ្សេងៗទៀត។

## សង្ខេបប្រតិបត្តិការរបស់ IFAD ចាប់តាំងពីឆ្នាំ ១៩៩៦

| | |
|---|---|
| គម្រោងវិនិយោគដែលបានអនុម័ត | ៩ (កម្ចីលើកទី១ដែលបានអនុម័តក្នុងឆ្នាំ១៩៩៦) |
| ចំនួនសរុបនៃហិរញ្ញបទានវិនិយោគ របស់ IFAD | (១៧៩,៥ លានដុលារអាមរិក (រួមទាំងជំនួយឥតសំណង DSF ចំនួន ៣៥ លានដុលារសហរដ្ឋអាមរិក និងចំនួន ១៥ លានដុល្លាររបស់ ASAP) |
| មូលនិធិរបស់ដៃគូ (រដ្ឋាភិបាល និងអ្នកទទួលផល) | ៧៥,៧ លានដុល្លារអាមេរិក |
| ចំនួនសហហិរញ្ញប្បទាន (ម្ចាស់សហហិរញ្ញប្បទានសំខាន់ៗ) | ៩៨,៧ លានដុលារអាមេរិក (ADB, ធនាគារពិភពលោក, អាល្លឺម៉ង់, ហ្វាំងឡង់, UNDP, FAO) |
| តម្លៃផលប័ត្រសរុប | ៣៥៣,៩ លានដុល្លារអាមេរិក |
| ចំនួន និងចំនួន ហិរញ្ញប្បទាន របស់ IFAD នៃគម្រោងកំពុងដំណើរការ (គិតត្រឹមខែសីហាឆ្នាំ ២០១៧) | ៤ (១២៨,៧ លានដុល្លារអាមេរិក) |
| ផ្តោតលើប្រតិបត្តិការ | COSOPទី១ (១៩៩៨-២០០៧): កសិកម្ម និងអភិវឌ្ឍន៍ជនបទក្នុងកម្មវិធីសិលា<br>COSOPទី២ (២០០៨-២០១២): កសិកម្មនិងការអភិវឌ្ឍជនបទក្នុងក្របខ័ណ្ឌ វិមជ្ឈការនិងវិសហមជ្ឈការ<br>COSOPទី៣ (២០១៣-២០១៨): លទ្ធភាពទទួលបានទីផ្សារ, ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងវិបត្តិ, ការពង្រឹងការផ្តល់សេវានៅតាមជនបទ<br>ចំណុចសំខាន់ចម្បងគឺៈការបណ្តុះបណ្តាលកសិកម្មសេវាផ្សព្វផ្សាយកសិកម្មគាំទ្រសម្រាប់វិមជ្ឈការនិងការផ្តល់សេវានៅតាមជនបទសេវាកម្មហិរញ្ញវត្ថុជនបទ ហេដ្ឋារចនាសម្ព័ន្ធជនបទ |
| យុទ្ធសាស្ត្រប្រចាំប្រទេស | ១៩៩៨; ២០០៨-២០១២; ២០១៣-២០១៨ |
| វត្តមានប្រចាំប្រទេសរបស់ IFAD | ចាប់តាំងពីឆ្នាំ២០០៨ មក។ បច្ចុប្បន្នមន្ត្រីកម្មវិធីប្រចាំប្រទេសមួយរូប។ កិច្ចព្រមព្រៀងប្រចាំប្រទេសដែលបានចុះហត្ថលេខានៅឆ្នាំ២០១៥ ។ កិច្ចព្រមព្រៀងកម្រិតសេវាកម្មជាមួយ UNOPS ។ |
| អ្នកគ្រប់គ្រងកម្មវិធីប្រចាំប្រទេស | Benoit Thierry (ឧសភា ២០១៤-); Khalid El-Harizi (មេសា ២០១១-); Youqiong Wang (១៩៩៧-២០១១) |
| ទីភ្នាក់ងារនាំមុខ និងភ្នាក់ងារដៃគូសំខាន់ៗ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ - គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី |

ASAP: ការបន្សាំទៅនឹងកម្មវិធីកសិកម្មខ្នាតតូច

COSOP: កម្មវិធីឱកាសយុទ្ធសាស្ត្រប្រចាំប្រទេស

DSF: ក្របខ័ណ្ឌនិរន្តរភាពបំណុល

## Kingdom of Cambodia

IFAD-supported operations since 1996

*Country strategy and programme evaluation*




The designations employed and the presentation of the material in this map do not imply the expression of any opinion whatsoever on the part of IFAD concerning the delimitation of the frontiers or boundaries, or the authorities thereof.

IFAD *Map compiled by IFAD | 24-01-2017*

# Cambodia timeline since 1991: country events and IFAD activities




| | | | |
|---|---|---|---|
| AIMS | Accelerated Integrated Markets for Smallhlders Project | PADEE | Project for Agiculture Development and Economic Empowerment |
| ASPIRE | Agriculture Services Programme for Innovation, Resilience and Extension | PPRP-EMR | Policy Document on Promotion of Paddy Rice Production and Export of Milled Rice |
| ASSDP | Agricultural Sector Strategic Development Plan | RPRP | Rural Poverty Reduction Project in Prey Veng and Svay Rieng |
| CBRDP | Community Based Rural Development Project in Kampong Thom and Kampot | RULIP | Rural Improvement Livelihoods Project in Kratie, Preah Vihear and Ratanakiri |
| CCSP | Climate Change Strategic Plan | SAW | Strategy for Agriculture and Water |
| COSOP | Country strategic opportunities paper/programme | SEDP | Socio Economic Development Plan |
| NPRS | National Poverty Reduction Strategy | SFDDR | Strategic Framework for Decentralization and De-Concentrtion Reforms |
| NP-SNDD | National Program for Sub-National Democratic Development | SPFLD | Strategic Planning Frameworkfor Livestock Development |
| NSDP | National Strategic Development Plan | TSSD | Tonle Sap Poverty Reduction and Smallholder Development Project |
| NSFSN | National Strategy for Food Security and Nutrition | | |